សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ៊្វូមី គូរ៉ូគី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព

របស់ប្រទេសជប៉ុនប្រចាំកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ

របស់ប្រទេសជប៉ុន

០៦ កុម្ភៈ ២០១២

**សូមគោរព លោក Petr SCHMIED ប្រធានបេសកម្ម"People in Need"ក្នុងព្រះរាជាណាចក្រកម្ពុជា!**
**សូមគោរព អស់លោក-លោកស្រី អ្នកតំណាងមណ្ឌលសុខភាពនានាក្នុងខេត្តតាកែវ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយ"People in Need" សម្រាប់គម្រោងសាងសង់បន្ទប់សម្រាលទារកក្នុងមណ្ឌលសុខភាពចំនួន៨ក្នុងខេត្តតាកែវ។

ខ្ញុំសូមស្វាគមន៍ចំពោះអ្នកតំណាងឲ្យ "People in Need" ដែលជាអង្គការក្រៅរដ្ឋាភិបាលរបស់សាធារណៈរដ្ឋឆែក និងតំណាងមណ្ឌលសុខភាពនានាក្នុងខេត្តតាកែវដែលអញ្ជើញមកចូលរួមក្នុងពិធី។

ជំនួយដែលមានថវិកាសរុបចំនួន ៧៤,៣៣៣ដុល្លាអាមេរិក ត្រូវបានផ្តល់ជូនសម្រាប់គម្រោងពង្រីកបន្ទប់សម្រាលទារកក្នុងមណ្ឌលសុខភាព៨ក្នុងខេត្តតាកែវ។ គម្រោងនេះនឹងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសម្រាលទារក និងសេវាថែទាំសុខភាពមាតានិងទារកមុននិងក្រោយសម្រាល។ វាក៏នឹងជួយសម្រួលផងដែរដល់ក្រុមគ្រួសារស្ត្រីឆ្លងទន្លេសម្រាប់ការស្នាក់នៅនិងមើលថែទាំពួកគេ ដែលនឹងលើកទឹកចិត្តស្ត្រីមានផ្ទៃពោះឲ្យទៅសម្រាលកូនក្នុងមណ្ឌលសុខភាព។

គម្រោងនេះគឺស្របទៅតាមផែនការយុទ្ធសាស្ត្រនៃវិស័យសុខាភិបាលរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍ផ្តល់ជំនួយអភិវឌ្ឍន៍នៃរដ្ឋាភិបាលជប៉ុន ដែលសុទ្ធតែផ្តោតជាសំខាន់ទៅលើការកាត់បន្ថយអត្រាមរណៈរបស់មាតានិងទារក។ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយបង្កើនសុវត្ថិភាពក្នុងពេលសម្រាល និងសេវាថែទាំសុខភាពសមរម្យនៅមណ្ឌលសុខភាព ហើយនិងរួមចំណែកកាត់បន្ថយអត្រាមរណៈរបស់មាតា និងទារកដែលនៅមានកម្រិតខ្ពស់នៅតាមតំបន់ជនបទ។

ខ្ញុំដឹងថាយើងធ្លាប់មានកិច្ចសហប្រតិបត្តិការជាមួយ "People in Need" តាមរយៈជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូចនៅប្រទេសអង់ហ្គូឡា និងអេត្យូពី។ ខ្ញុំជឿជាក់ថា "People in Need" នឹងអនុវត្តគម្រោងនេះយ៉ាងមានប្រសិទ្ធភាពសម្រាប់ជាគុណប្រយោជន៍ដល់ប្រជាជនក្នុងខេត្តតាកែវ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!